ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋាន

លេខ..០៥៤៤./០៤៤២៤៤/អ.ពស.សបដ.ឌិប

# ដីកាបញ្ជូន

គោរពជូន: - គណៈកម្មការជំនាញទាំង១០ព្រឹទ្ធសភា
- អគ្គនាយកដ្ឋានទាំង៥
- នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ
- នាយកដ្ឋានស្រាវជ្រាវកិច្ចការអន្តរជាតិ

| ល.រ | រាយមុខលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ០១ | របាយការណ៍សកម្មភាពការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៤របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ (ច្បាប់ថតចម្លង) | ០១ច្បាប់ | "ដើម្បីជូនជ្រាបជាព័ត៌មាន" |

ថ្ងៃ សុក្រ ៣ រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០២៤

ជ.អគ្គលេខាធិការ

អគ្គលេខាធិការរង

ខេង សិទ្ធិគុណា

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: secretariat@senate.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

លេខ៖ ៦១៤ កបទ.សអ.គកផ.

# របាយការណ៍សកម្មភាពការងារ
# ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
# ប្រចាំត្រីមាសទី១ ឆ្នាំ២០២៤

ក្នុងត្រីមាសទី១ ឆ្នាំ២០២៤ នេះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (កបទ.សអ.) បានខិតខំបំពេញការងារការទូត ដោយអនុលោមតាមបាវចនារបស់រាជរដ្ឋាភិបាល **«កំណែទម្រង់ខាងក្នុង កសាងមិត្តខាងក្រៅក្នុងស្មារតីឯករាជ្យ»** ដើម្បីពង្រឹងនិងពង្រីកទំនាក់ទំនងក្នុងក្របខ័ណ្ឌទ្វេភាគីនិងពហុភាគី ព្រមទាំងលើកកម្ពស់វិបុលភាព សន្តិភាព កិត្យានុភាព និងចូលរួមដោះស្រាយបញ្ហាប្រឈមសកលរួម តាមរយៈសកម្មភាពការងារធំៗទាំងប្រាំ រួមមាន៖

<u>ការងារទី១៖</u> ការការពារផលប្រយោជន៍ជាតិ ជាពិសេសការការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី

**១.១. ការការពារកិត្តិយស និងសេចក្តីថ្លៃថ្នូរជាតិ**

ក្រសួងបាននិងកំពុងបំពេញការងារយ៉ាងសកម្មក្នុងការលើកតម្កើងកិត្តិនាមរបស់កម្ពុជា ដោយចូលរួមជាមួយសហគមន៍អន្តរជាតិ ដើម្បីបញ្ជាក់និងពង្រឹងជំហរលើបញ្ហាសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងគោលនយោបាយការបរទេស។ ក្រសួងបានឆ្លើយតប និងកែតម្រូវអត្ថបទចំនួនពីររបស់ The Diplomat ដែលមានចំណងជើងថា « Why Cambodia Needs to Incoperate More Women Into Its Foreign Policy Process» និង « US Sanctions and Rallying Around the Flag in Noth Korea and Cambodia»។ ជាងនេះទៅទៀត ក្រសួងបានចេញសេចក្តីបំភ្លឺចំពោះការផ្សាយរបស់វិទ្យុបារាំងអន្តរជាតិ ក្រោមចំណងជើងថា «កម្ពុជាទាត់ចោលការវិភាគថា អាមេរិកនឹងដាក់ទណ្ឌកម្មកម្ពុជាដូចកូរ៉េខាងជើង»។

**១.២. ការការពារបូរណភាពទឹកដី៖**

ក្រសួងបានបន្តសហការជាមួយក្រសួង/ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាព្រំដែនដែលនៅសេសសល់ សំដៅប្រែក្លាយតំបន់ព្រំដែនទៅជាព្រំដែនសន្តិភាព កិច្ចសហប្រតិបត្តិការល្អ និងការអភិវឌ្ឍប្រកបដោយចីរភាព ក្នុងនោះ៖

- **ព្រំដែនកម្ពុជា-ឡាវ៖** ក្រសួងបានចូលរួមរៀបចំដំណើរការផ្លាស់ប្តូរលិខិតុបករណ៍ផ្តល់សច្ចាប័នលើសន្ធិសញ្ញាព្រំដែនជាមួយប្រទេសឡាវ ក្នុងអំឡុងពេលដំណើរទស្សនកិច្ចផ្លូវការរបស់ សម្តេចធិបតី

នាយករដ្ឋមន្ត្រី នៅឡាវនៅថ្ងៃទី២៥-២៦ ខែមីនា ឆ្នាំ២០២៤។ ក្រសួងក៏បានសម្របសម្រួលកិច្ចការផ្សេងៗ ដូចជារៀបចំកិច្ចប្រជុំគណៈកម្មការចម្រុះព្រំដែន និងការចុះត្រួតពិនិត្យបង្គោលព្រំដែនជាក់ស្តែង។

- ❖ ព្រំដែនកម្ពុជា-ថៃ៖ ក្រសួងបានចូលរួមសិក្សាលើបញ្ហាការគ្រប់គ្រងច្រកទ្វារព្រំដែន ជាពិសេសច្រកប្រាសាទព្រះវិហារ និងសម្របសម្រួលកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែន។ ក្រសួងក៏បានរៀបចំការតវ៉ាឆ្លើយតបទៅនឹងការចាប់ទូក និងអ្នកនេសាទកម្ពុជា និងចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចប្រជុំគណៈកម្មការព្រំដែន។
- ❖ ព្រំដែនកម្ពុជា-វៀតណាម៖ ក្រសួងបានសម្របសម្រួលបញ្ហាទាក់ទងនឹងសំណើថែរក្សាបង្គោលព្រំដែនប្រវត្តិសាស្ត្រ និងត្រួតពិនិត្យការសាងសង់នៅតាមព្រំដែន។

**១.៣. កិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលបរទេស ដើម្បីផលប្រយោជន៍ជាតិ**

គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤ រាជរដ្ឋាភិបាលកម្ពុជាបានឯកភាពចុះអនុស្សរណៈនៃការយោគយល់គ្នា (MOU) រវាង កបទ.សអ. និងអង្គការមិនមែនរដ្ឋាភិបាលបរទេស (FNGOs) សរុបចំនួន៣៤៤អង្គការ (ចុះបញ្ជីថ្មីចំនួន៥ និងបន្តសុពលភាពចំនួន៣៣៦) សំដៅជានាដល់ការបំពេញបេសកកម្មប្រកបដោយតម្លាភាព និងជួយរួមចំណែកដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា។

**១.៤. ការការពារផលប្រយោជន៍ពលរដ្ឋខ្មែរនៅបរទេស**

កបទ.សអ. និងស្ថានតំណាងកម្ពុជាប្រចាំនៅបរទេស បានបន្តយកចិត្តទុកដាក់ខ្ពស់ ក្នុងការការពារផលប្រយោជន៍ និងសុខុមាលភាពពលរដ្ឋខ្មែរនៅបរទេស តាមរយៈកិច្ចខិតខំសម្របសម្រួលជួយសង្គ្រោះ និងធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែរ ឱ្យត្រឡប់មកកម្ពុជាវិញសរុបចំនួន ២៨៥ នាក់ (ស្រី៖ ១៤៤ នាក់) ពីប្រទេសថៃ ចិន ជប៉ុន មីយ៉ាន់ម៉ា និងវៀតណាម។

**<u>ការងារទី២</u>៖ ការអនុវត្តគោលនយោបាយការបរទេសប្រកបដោយភាពបត់បែន វាងវៃ ឆ្លើយតបទៅនឹងសម្ពាធភូមិសាស្ត្រនយោបាយ**

**២.១. ទំនាក់ទំនងទ្វេភាគី**

នៅត្រីមាសទី១ ឆ្នាំ២០២៤នេះ សកម្មភាពការទូតជាយុទ្ធសាស្ត្របន្តបន្ទាប់របស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ ចិន្តាសោភា** និងថ្នាក់ដឹកនាំនិងមន្ត្រីក្រសួងកបទ.សអ. បាននិងកំពុងពង្រឹងទំនាក់ទំនងកាន់តែស៊ីជម្រៅជាមួយភាគីមិត្តជុំវិញពិភពលោក។ សកម្មភាពទាំងនេះត្រូវបានសម្គាល់ដោយការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសំខាន់ៗ និងការពិភាក្សាស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យផ្សេងៗ រាប់បញ្ចូលទាំងគំនិតផ្តួចផ្តើមកំណើនបៃតង រហូតដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។ សកម្មភាពទាំងនោះ រួមមាន៖

- ❖ **ក្នុងតំបន់អាស៊ី និងអូសេអានី៖**
  - **ជាមួយថៃ៖ សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានបំពេញទស្សនកិច្ចផ្លូវការកាលពីថ្ងៃទី០៧ ខែកុម្ភៈ ដោយបានជួបពិភាក្សាគ្នាយ៉ាងស៊ីជម្រៅលើវិស័យជាច្រើននៃកិច្ចសហប្រតិបត្តិការទ្វេភាគី និងទំនាក់ទំនងរវាងប្រជាជននិងប្រជាជន ជាមួយឯកឧត្តមនាយករដ្ឋមន្ត្រីថៃ **សេដ្ឋា ថាវីស៊ីន**។

ក្រៅពីការប្រកាសដំឡើងកម្រិតនៃទំនាក់ទំនងទ្វេភាគីទៅជា «**ភាពជាដៃគូយុទ្ធសាស្ត្រ**» នាយករដ្ឋមន្ត្រីទាំងពីរក៏បានធ្វើជាសាក្សីការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាចំនួន៥ រួមមានៈ (១) កិច្ចសហប្រតិបត្តិការលើវិស័យកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការឆ្លើយតបគ្រោះអាសន្ន (២) កិច្ចសហប្រតិបត្តិការលើវិស័យសិក្សាធិការ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (៣) ទំនិញឆ្លងកាត់ (៤) MoU រវាងសភាពាណិជ្ជកម្មកម្ពុជា និងធនាគារនាំចេញ-នាំចូលថៃ (៥) MoU រវាងសភាពាណិជ្ជកម្មកម្ពុជា និងគណៈកម្មាធិការពាណិជ្ជកម្មថៃ។ ក្រៅពីនេះ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ក៏បានទទួលជួបសម្តែងការគួរសមជាមួយ **ឯកឧត្តម វ៉ាន់ មូហាម៉ាត់ ណ មះថា** ប្រធានសភាថៃ (ថ្ងៃទី២២ ខែមីនា) និងលោកជំទាវ **ផេថងថាន ស៊ីណាវ៉ាត់ត្រា** អនុប្រធានគណៈកម្មការជាតិទទួលបន្ទុកជំរុញអំណាចទន់ និងជាប្រធានគណបក្សភឿថៃ (ថ្ងៃទី១៨ ខែមីនា) នៅវិមានសន្តិភាពផងដែរ។

- **ជាមួយម៉ាឡេស៊ីៈ សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានបំពេញទស្សនកិច្ចផ្លូវការ កាលពីថ្ងៃទី២៧ ខែកុម្ភៈ និងបានពិភាក្សាយ៉ាងស៊ីជម្រៅអំពីកិច្ចសហប្រតិបត្តិការលើវិស័យជាច្រើន ដែលផ្តល់ប្រយោជន៍ឱ្យគ្នាទៅវិញទៅមកជាមួយ**ឯកឧត្តមនាយករដ្ឋមន្ត្រី អាន់វ៉ា អ៊ីប្រាហ៊ីម**។ នាយករដ្ឋមន្ត្រីទាំងពីរ ក៏បានធ្វើជាសាក្សីក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងសភាពាណិជ្ជកម្មនៃប្រទេសទាំងពីរ និងពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម។
- **ជាមួយឡាវៈ សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានបំពេញទស្សនកិច្ចផ្លូវការ កាលពីថ្ងៃទី២៥-២៦ ខែមីនា ដែលក្នុងនោះថ្នាក់ដឹកនាំនៃប្រទេសទាំងពីរបានអះអាងជាថ្មីនូវការប្តេជ្ញាចិត្តចំពោះភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយនិងយូរអង្វែង ដោយផ្តោតលើកិច្ចសហប្រតិបត្តិការផ្នែកនយោបាយ ថាមពល ពាណិជ្ជកម្ម និងសន្តិសុខ។ កម្ពុជា-ឡាវគ្រោងនឹងបង្កើនពាណិជ្ជកម្ម និងទេសចរណ៍ តាមរយៈគំនិតផ្តួចផ្តើម «ប្រទេសបី គោលដៅតែមួយ» ជាមួយវៀតណាម និងធ្វើឱ្យប្រសើរឡើងនូវការតភ្ជាប់រវាងប្រទេសទាំងពីរ។ លើសពីនេះ ថ្នាក់ដឹកនាំទាំងពីរបានធ្វើជាសាក្សីក្នុងការផ្លាស់ប្តូរលិខិតុបករណ៍សច្ចាប័ននៃសន្ធិសញ្ញាព្រំដែនដែលបានចុះហត្ថលេខាក្នុងឆ្នាំ២០២៣ ដែលបង្ហាញពីវឌ្ឍនភាពក្នុងទំនាក់ទំនងទ្វេភាគី និងកិច្ចខិតខំប្រឹងប្រែងធ្វើសមាហរណកម្មក្នុងតំបន់។
- **ជាមួយជប៉ុនៈ** នៅក្នុងកិច្ចពិភាក្សាទ្វេភាគីនៅថ្ងៃទី១៣ ខែមីនា ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ ចិន្តាសោភា** និង ឯកឧត្តមអនុរដ្ឋមន្ត្រីការបរទេសជប៉ុន **កុមីរ៉ា ម៉ាសាហ៊ីរ៉ូ** បានអះអាងជាថ្មីនូវការប្តេជ្ញាចិត្តចំពោះសន្តិភាព និងការអភិវឌ្ឍក្នុងតំបន់។ ភាគីទាំងពីរ បានចុះហត្ថលេខាលើលិខិតប្តូរសារ និងឯកសារពាក់ព័ន្ធស្តីពីការផ្តល់ឥណទានសម្បទានប្រាក់យ៉េន ដែលមានទឹកប្រាក់ចំនួន២១.១០៤លានយ៉េន (ប្រមាណ១៥៤លានដុល្លារអាម៉េរិក) សម្រាប់អនុវត្តគម្រោងអភិវឌ្ឍន៍មន្ទីរពេទ្យក្នុងតំបន់។

ក្រៅពីនេះ នៅក្នុងព្រឹត្តិការណ៍អមនៃកិច្ចប្រជុំកំពូលអាស៊ាន-អូស្ត្រាលី កាលពីថ្ងៃទី២-៦ ខែមីនា **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានជួបជាមួយប្រមុខរដ្ឋាភិបាលនៃប្រទេសជាច្រើន រួមមានៈ សិង្ហបុរី ហ្វីលីពីន ឥណ្ឌូណេស៊ី អូស្ត្រាលី នូវែលសេឡង់ និងវៀតណាម ដែលមានខ្លឹមសារសំខាន់ៗ ដូចខាងក្រោមៈ

- **ជាមួយសិង្ហបុរី៖** កិច្ចសហប្រតិបត្តិការបានផ្តោតសំខាន់លើកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអប់រំ គំនិតផ្តួចផ្តើមថាមពលកកើតឡើងវិញ និងការអភិវឌ្ឍទេសចរណ៍ រួមទាំងគំនិតផ្តួចផ្តើមនៃបណ្តាញថាមពលអាស៊ានសម្រាប់សន្តិសុខថាមពលក្នុងតំបន់។
- **ជាមួយអូស្ត្រាលី៖** ភាគីទាំងពីរបានព្រមព្រៀងគ្នាក្នុងការស្វែងរកឱកាសពង្រីកពាណិជ្ជកម្ម និងវិនិយោគបន្ថែមទៀត ដោយផ្តោតជាពិសេសលើការស្រាវជ្រាវវិទ្យាសាស្ត្រ និងកសិកម្មព្រមទាំងការដឹកជញ្ជូនតាមផ្លូវអាកាស និងទេសចរណ៍។
- **ជាមួយនូវែលហ្សេឡង់៖** ភាគីទាំងពីរបានបង្ហាញពីគោលបំណងចង់បង្កើនទំហំពាណិជ្ជកម្ម និងការវិនិយោគ ជាពិសេសលើវិស័យកសិកម្ម និងកសិឧស្សាហកម្ម និងគាំទ្រដល់គោលដៅរបស់កម្ពុជាក្នុងការការប្រែក្លាយជាប្រទេសគ្មានមីននៅឆ្នាំ២០២៥។
- **ជាមួយហ្វីលីពីន៖** ភាគីទាំងពីរបានឯកភាពគ្នាលើការរៀបចំកិច្ចប្រជុំលើកទី៤ នៃគណៈកម្មការចម្រុះសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីនៅឆមាសទីពីរនៃឆ្នាំ២០២៤ និងបានប្តេជ្ញាចិត្តក្នុងការបង្កើនពាណិជ្ជកម្មទ្វេភាគី ជាពិសេសលើអង្ករ និងផលិតផលកសិកម្ម ផ្សេងទៀត និងការជំរុញភាពជាដៃគូធុរកិច្ចប្រទេសទាំងពីរ ដើម្បីជំរុញទេសចរណ៍តាមរយៈការធ្វើឱ្យប្រសើរឡើងនូវការតភ្ជាប់ រួមទាំងការហោះហើរត្រង់រវាងគោលដៅទេសចរណ៍សំខាន់ៗនៃប្រទេសទាំងពីរ។
- **ជាមួយឥណ្ឌូណេស៊ី៖** ក្នុងឱកាសខួបលើកទី៦៥នៃទំនាក់ទំនងការទូត ភាគីទាំងពីរ បានគូសបញ្ជាក់ពីការប្តេជ្ញាចិត្តពង្រឹងកិច្ចសហប្រតិបត្តិការឱ្យកាន់តែស៊ីជម្រៅ លើវិស័យសក្តានុពលជាច្រើន ដូចជាកសិកម្ម ពាណិជ្ជកម្ម វិនិយោគ និងជំរុញការតភ្ជាប់រវាងប្រជាជននិងប្រជាជន ព្រមទាំងការជំរុញការវិនិយោគរបស់វិស័យឯកជននៅក្នុងហេដ្ឋារចនាសម្ព័ន្ធរបស់កម្ពុជា ជាពិសេសពីសំណាក់ក្រុមហ៊ុនឥណ្ឌូណេស៊ី។
- **ជាមួយវៀតណាម៖** ថ្នាក់ដឹកនាំទាំងពីរបានពិភាក្សាអំពីការរៀបចំកិច្ចប្រជុំកំពូលត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម និងសារៈសំខាន់នៃកិច្ចប្រជុំទៀងទាត់សម្រាប់កិច្ចការបរទេស សន្តិសុខ និងការពារជាតិ។ កិច្ចពិភាក្សាក៏បានផ្តោតលើកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច សំដៅសម្រេចគោលដៅពាណិជ្ជកម្មទ្វេភាគីចំនួន ២០ ពាន់លានដុល្លារអាមេរិក និងពង្រឹងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ រួមទាំងការអភិវឌ្ឍផ្លូវល្បឿនលឿនភ្នំពេញ-បាវិត-ម៉ុកបាយ-ហូជីមិញ។ បន្ថែមពីលើនេះ ថ្នាក់ដឹកនាំទាំងពីរក៏បានព្រមព្រៀងគ្នាក្នុងការលើកកម្ពស់វិស័យទេសចរណ៍តាមរយៈគំនិតផ្តួចផ្តើម «ប្រទេសទាំងបី គោលដៅតែមួយ»។

❖ **ក្នុងតំបន់អឺរ៉ុប និងអាម៉េរិក៖**

- **ជាមួយបារាំង៖** សម្តេចធិបតីនាយករដ្ឋមន្ត្រី បានបំពេញទស្សនកិច្ចផ្លូវការ កាលពីថ្ងៃទី១៨-១៩ ខែមករា។ នៅក្នុងជំនួបជាមួយឯកឧត្តមប្រធានាធិបតី **អេម៉ានូអែល ម៉ាក្រុង** និងឯកឧត្តមនាយករដ្ឋមន្ត្រី **ហ្គាប្រៀល អាតតាល់** ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ បានឯកភាពគ្នាលើកកម្ពស់ទំនាក់ទំនងទ្វេភាគី ក្នុងគោលដៅសម្រេចឱ្យបាននូវភាពជាដៃគូយុទ្ធសាស្ត្ររវាងប្រទេសទាំងពីរ និងឆ្ពោះទៅកំណត់ផែនការសកម្មភាព ក្នុងការសម្រេចបាននូវគោលដៅដែលបានកំណត់។

- ជាមួយសហរដ្ឋអាមេរិកៈ សម្ដេចធិបតីនាយករដ្ឋមន្ត្រី បានទទួលជួបជាមួយ ឯកឧត្តម ដានីញែល គ្រីតិនប្រ៊ីង ឧបការីរដ្ឋមន្ត្រីការបរទេសអាមេរិកទទួលបន្ទុកកិច្ចការអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក កាលពីថ្ងៃទី២៦ ខែកុម្ភៈ ដើម្បីពិភាក្សាអំពីការពង្រឹងទំនាក់ទំនងក្នុងវិស័យពាណិជ្ជកម្ម វិនិយោគ និងសន្តិសុខ។ កិច្ចសន្ទនានេះក៏បានផ្ដោតលើការសម្របសម្រួលរបស់កម្ពុជាក្នុងទំនាក់ទំនង អាស៊ាន-អាមេរិក ចាប់ពីខែកក្កដា ឆ្នាំ២០២៤ ដល់ខែកក្កដា ឆ្នាំ២០២៧។
- **ជាមួយលិចតិនស្តាញៈ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជួបពិភាក្សាការងារជាមួយលោកជំទាវ **ដូមីនីក ហាស្លើរ** ក្នុងដំណើរទស្សនកិច្ចផ្លូវការរបស់លោកជំទាវនៅកម្ពុជា កាលពីថ្ងៃទី២៩ ខែកុម្ភៈ។ កម្ពុជា និងលិចតិនស្តាញ បានពង្រឹងភាពជាដៃគូដោយចុះហត្ថលេខាលើកិច្ចព្រមព្រៀង ក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដែលមានគោលបំណងលើកកម្ពស់ការអភិវឌ្ឍ ធនធានមនុស្ស និងកំណត់ដំណាក់កាលសម្រាប់កិច្ចព្រមព្រៀងបន្ថែមទៀត។ នេះជាដំណើរ ទស្សនកិច្ចជាប្រវត្តិសាស្ត្ររបស់រដ្ឋមន្ត្រីការបរទេសលិចតិនស្តាញ មកកាន់ប្រទេសកម្ពុជា ដែល បានបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ប្រទេសទាំងពីរក្នុងការពង្រឹងទំនាក់ទំនងក្នុងវិស័យអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងវិស័យសក្តានុពលផ្សេងទៀត។
- **សហភាពអឺរ៉ុបៈ** ដំណើរទស្សនកិច្ចរបស់ស្នងការអឺរ៉ុប លោកជំទាវ **ជូតា អេកើលឡៃនិន** មកកម្ពុជា បានបង្ហាញពីព្រឹត្តិការណ៍ដ៏សំខាន់មួយក្នុងទំនាក់ទំនងកម្ពុជា-សហភាពអឺរ៉ុប ជាមួយនឹងការ ចុះហត្ថលេខាលើកិច្ចព្រមព្រៀងសំខាន់ៗចំនួន៤ និងការផ្តួចផ្តើមគម្រោងកំណើនបៃតង និងការងារដែលមានតម្លៃទឹកប្រាក់ចំនួន១.៤៣ាន់លានអឺរ៉ូ។ ក្នុងជំនួបទ្វេភាគី **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់ថាកិច្ចខិតខំប្រឹងប្រែងទាំងនេះ បញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ សហភាពអឺរ៉ុបក្នុងការគាំទ្រគោលដៅអភិវឌ្ឍន៍របស់កម្ពុជា រួមទាំងការផ្លាស់ប្តូររបស់កម្ពុជា ពីប្រទេសអភិវឌ្ឍតិចតួចនៅឆ្នាំ២០២៩ និងពង្រឹងទំនាក់ទំនងទ្វេភាគី។

ទន្ទឹមនេះ ទស្សនកិច្ចរបស់ឯកឧត្តមរដ្ឋលេខាធិការ **ចែម វីឡា** នៅតួកគី ថ្ងៃទី១៩-២០ ខែមីនា បានជំរុញសន្ទុះទំនាក់ទំនងការទូតទ្វេភាគី តាមរយៈកិច្ចប្រជុំលើកទី៣ នៃការពិគ្រោះយោបល់នយោបាយ ទ្វេភាគី ដែលមានគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការទៅវិញទៅមក ដោយសង្កត់ធ្ងន់ជាពិសេស លើការអភិវឌ្ឍពាណិជ្ជកម្ម និងសេដ្ឋកិច្ច។

## ២.២. កិច្ចសហប្រតិបត្តិការពហុភាគីៈ

ក្នុងត្រីមាសទី១ ឆ្នាំ២០២៤នេះ ថ្នាក់ដឹកនាំកម្ពុជាបានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចប្រជុំកំពូល និងវេទិកាសំខាន់ៗ ដើម្បីពិភាក្សា និងរៀបចំអនាគតនៃកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងពិភពលោក។ ការពិភាក្សាទាំងនេះបានលាតសន្ធឹងលើប្រធានបទជាច្រើន រួមមានភាពធន់សេដ្ឋកិច្ច ការអភិវឌ្ឍ ប្រកបដោយចីរភាព និងការលើកកម្ពស់សន្តិភាព និងស្ថិរភាព។ តាមរយៈកិច្ចសន្ទនាទាំងនេះ កម្ពុជាបាន ពង្រឹងការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះពហុភាគីនិយម និងវិបុលភាពរួម ទន្ទឹមនឹងនោះក៏សង្កត់ធ្ងន់លើ សារៈសំខាន់នៃការអភិរក្សវប្បធម៌ និងការផ្លាស់ប្តូរការអប់រំផងដែរ។ កិច្ចការទាំងនោះរួមមានៈ

❖ អាស៊ាន៖

**សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានចូលរួមកិច្ចប្រជុំកំពូលពិសេសអាស៊ាន-អូស្ត្រាលី ដើម្បីប្រារព្ធខួបលើកទី៥០នៃទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-អូស្ត្រាលី កាលពីថ្ងៃទី៤-៦ ខែមីនា នៅម៉ែលប៊ន។ កិច្ចប្រជុំបានអនុម័តឯកសារសំខាន់ៗចំនួនពីរ គឺ៖ (១) «**សេចក្តីថ្លែងការណ៍ចក្ខុវិស័យរបស់ថ្នាក់ដឹកនាំអាស៊ានអូស្ត្រាលី៖ ដៃគូសម្រាប់សន្តិភាព និងវិបុលភាព**» និង (២) «**សេចក្តីថ្លែងការណ៍ទីក្រុងម៉ែលប៊ន៖ ភាពជាដៃគូសម្រាប់អនាគត**»។ កិច្ចប្រជុំកំពូល ក៏បានសង្កត់ធ្ងន់លើសារៈសំខាន់នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មពហុភាគីដូចជា AANZFTA និង RCEP ការផ្លាស់ប្តូរការអប់រំតាមរយៈគំនិតផ្តួចផ្តើមដូចជាអាហារូបករណ៍ Aus4ASEAN និងការគាំទ្រផ្នែកអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ។

ដោយឡែកនៅថ្ងៃទី ២៨-២៩ ខែមករា **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** សុខ ចិន្តាសោភា បានចូលរួមកិច្ចប្រជុំចង្អៀតរដ្ឋមន្ត្រីការបរទេសអាស៊ាននៅប្រទេសឡាវ ដោយផ្តោតលើ «**ការពង្រឹងការតភ្ជាប់ និងភាពធន់**»។ កិច្ចប្រជុំនេះបានពិនិត្យឡើងវិញនូវលទ្ធផលនៃកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៣ ពិភាក្សាអំពីចក្ខុវិស័យ សហគមន៍អាស៊ានឆ្នាំ២០៤៥ និងបានផ្លាស់ប្តូរទស្សនៈស្តីពីទំនាក់ទំនងទ្វេភាគីខាងក្រៅរបស់អាស៊ាន និងបញ្ហាតំបន់ និងពិភពលោក។ លើសពីនេះ នៅថ្ងៃទី២ ខែកុម្ភៈ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានចូលរួមក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-សហភាពអឺរ៉ុបលើកទី២៤ នៅទីក្រុងព្រុចសែល ដែលក្នុងឱកាសនោះ រដ្ឋមន្ត្រីការបរទេសទាំងអស់បានគូសបញ្ជាក់អំពីសារៈសំខាន់នៃទំនាក់ទំនងអាស៊ាន-សហភាពអឺរ៉ុប និងបានពិភាក្សាអំពីការពង្រឹងភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-សហភាពអឺរ៉ុប។

❖ **កិច្ចសហប្រតិបត្តិការមេគង្គ៖**

ក្នុងសារអបអរសាទរខួបលើកទី៨ សម្រាប់សប្តាហ៍កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង (MLC) ឆ្នាំ២០២៤ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានលើកឡើងពីភាពជោគជ័យ MLC ជាគំរូសម្រាប់កិច្ចសហប្រតិបត្តិការឈ្នះ-ឈ្នះ និងការអភិវឌ្ឍប្រកបដោយចីរភាព។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់អំពីភាពធន់របស់ MLC ចំពេលមានបញ្ហាប្រឈមភូមិសាស្ត្រនយោបាយ និងការប្តេជ្ញាចិត្តក្នុងការជំរុញខ្សែក្រវាត់អភិវឌ្ឍន៍សេដ្ឋកិច្ច Lancang-Mekong តាមរយៈវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងឧស្សាហកម្ម រួមទាំងវិស័យថាមពលថ្មី។ ជាងនេះទៅទៀត ការអនុម័តផែនការសកម្មភាពប្រាំឆ្នាំថ្មី (២០២៣-២០២៧) និងគំនិតផ្តួចផ្តើមដូចជាគេហទំព័រឯកអគ្គរដ្ឋទូតទេសចរមេគង្គ-ឡានឆាង ត្រូវបានកត់សម្គាល់ថាជាជំហានសំខាន់បន្ថែមទៀត ឆ្ពោះទៅរកការចូលរួមរបស់យុវជន និងជំរុញការបង្កើតថ្មី។

❖ **ហ្វ្រង់កូហ្វូនី៖**

នៅថ្ងៃទី១៥ ខែមករា នៅទីក្រុងប៉ារីស **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានជួបជាមួយលោកជំទាវ **ល្វីស មូស្ស៊ីគីវ៉ាបូ** អគ្គលេខាធិការនៃអង្គការហ្វ្រង់កូហ្វូនី ដែលបានលើកឡើងគាំទ្រការដាក់បេក្ខភាពរបស់កម្ពុជាសម្រាប់កិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីឆ្នាំ២០២៦ និងពិភាក្សាអំពីការអភិរក្សភាសា និងវប្បធម៌បារាំង។ ជំនួបនេះក៏បានកត់សម្គាល់នូវការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសំខាន់ៗរវាងសភាពាណិជ្ជកម្មកម្ពុជា និងសហព័ន្ធនិយោជកហ្វ្រង់កូហ្វូនី។

❖ កិច្ចសហប្រតិបត្តិការផ្សេងៗ៖

- **វេទិកាសេដ្ឋកិច្ចពិភពលោក៖** នៅក្នុងវេទិកាសេដ្ឋកិច្ចពិភពលោកលើកទី៥៤ នៅទីក្រុងដាវ៉ូស នៅថ្ងៃទី១៦-១៧ ខែមករា **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានសង្កត់ធ្ងន់ពីតម្រូវការសម្រាប់តម្លាភាព ស្ថិរភាព និងគណនេយ្យភាព ដើម្បីកសាងទំនុកចិត្តពិភពលោកឡើងវិញ។ **សម្តេចធិបតី** បានជំរុញឱ្យថ្នាក់ដឹកនាំពិភពលោកជំរុញសន្តិភាព និងការស្តារសេដ្ឋកិច្ចឡើងវិញសម្រាប់ភាពល្អជាសមូហភាព ដោយឆ្លុះបញ្ចាំងពីការទទួលខុសត្រូវដ៏សំខាន់របស់គ្រប់រដ្ឋាភិបាល វិស័យឯកជន និងអង្គការក្រៅរដ្ឋាភិបាល។
- **វេទិកាថ្នាក់រដ្ឋមន្ត្រីសហភាពអឺរ៉ុប-តំបន់ឥណ្ឌូប៉ាស៊ីហ្វិក៖ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** នៅថ្ងៃទី១-២ ខែកុម្ភៈ បានចូលរួមវេទិកាថ្នាក់រដ្ឋមន្ត្រីសហភាពអឺរ៉ុប-ឥណ្ឌូប៉ាស៊ីហ្វិកលើកទី៣ នៅប្រទេសបែលហ្ស៊ិក ដែលផ្តោតលើប្រធានបទនៃភាពរុងរឿង ភាពធន់សេដ្ឋកិច្ច ការវិនិយោគបៃតង និងការដោះស្រាយបញ្ហាប្រឈមភូមិសាស្ត្រនយោបាយ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានគូសបញ្ជាក់អំពីការជំរុញភាពធន់សេដ្ឋកិច្ច និងយុទ្ធសាស្ត្រវិនិយោគ។

ការងារទី៣៖ **ការអនុវត្តការងារការទូតសេដ្ឋកិច្ច និងវប្បធម៌**

ក្រសួង និងស្ថានតំណាងកម្ពុជានៅបរទេសបាននិងកំពុងចូលរួមយ៉ាងសកម្ម ក្នុងបេសកកម្មលើកកម្ពស់ផលប្រយោជន៍សេដ្ឋកិច្ច និងវប្បធម៌របស់កម្ពុជានៅលើឆាកអន្តរជាតិ ជាក់ស្តែង ASEAN-India Bazaar 2024 នៅប្រទេសឥណ្ឌូណេស៊ី និងទិវាវប្បធម៌ជាតិលើកទី២៤ នៅសាធារណរដ្ឋកូរ៉េ បានផ្តល់ឱកាសពិសេសសម្រាប់កម្ពុជា ដើម្បីបង្ហាញបេតិកភណ្ឌវប្បធម៌ដ៏សម្បូរបែប និងផលិតផលចម្រុះ។ លើសពីនេះ ការរៀបចំកម្មវិធីវេទិកាការទូតសេដ្ឋកិច្ច ក្រោមប្រធានបទ «Cambodia's New Page: Business and Investment Opportunities» នៅប្រទេសថៃ និងជំនួបធុរកិច្ចជាមួយធុរជនជាច្រើននៅប្រទេសប្រ៊ុយណេ និងបារាំង បានជំរុញទំនាក់ទំនងវិនិយោគ និងពាណិជ្ជកម្មកម្ពុជាជាមួយប្រទេសដៃគូ។

ការងារទី៤៖ **ការចូលរួមក្នុងបុព្វហេតុសន្តិភាព ស្ថិរភាព និងដំណោះស្រាយបញ្ហាប្រឈមនានានៅក្នុងពិភពលោក**

គិតត្រឹមត្រីមាសទី១ ឆ្នាំ២០២៤ នេះ កម្ពុជាមានកងកម្លាំងរក្សាសន្តិភាពក្រោមឆត្រ អ.ស.ប. ចំនួន៦៤០នាក់ (ស្ត្រី៖១២៤នាក់) កំពុងបំពេញបេសកកម្មនៅប្រទេសចំនួន៦ រួមមាន៖ លីបង់ ម៉ាលី ស៊ូដង់ ស៊ូដង់ខាងត្បូង កុងហ្គោ និងសាធារណរដ្ឋអាហ្វ្រិកកណ្តាល។

ទន្ទឹមនេះ ឈរលើស្មារតីចូលរួមចំណែកក្នុងបុព្វហេតុសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចពិភពលោក ក៏ដូចជាសមាហរណកម្មកម្ពុជាចូលទៅក្នុងសហគមន៍អន្តរជាតិ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានឯកភាពដាក់កម្ពុជាជាបេក្ខភាពសមាជិកស្ថាប័នអ.ស.ប.ចំនួន២ គឺ៖ (១) គណៈកម្មាធិការគ្រប់គ្រងនៃគណៈកម្មការកសាងសន្តិភាព អ.ស.ប. (OCPBC) សម្រាប់អាណត្តិ ២០២៥-២០២៦ ដោយមានប្រទេសចំនួន៨៤ សម្រេចគាំទ្រ និង (២) ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម (ECOSOC) សម្រាប់អាណត្តិ ២០២៨-២០៣០ ដែលមានប្រទេសចំនួន៦០ សម្រេចគាំទ្រ (គិតត្រឹមថ្ងៃទី៣១ ខែមីនា)។

ការងារទី៥៖ ការបន្តការដ្ឋានកំណែទម្រង់ស្ថាប័ននៅក្នុងក្រសួង ដើម្បីរៀបចំអង្គអ្នកការទូតប្រកបដោយវិជ្ជាជីវៈ ស្នេហាជាតិ សកម្ម និងមានសមត្ថភាព

ក្នុងស្មារតីលើកកម្ពស់ការងារអភិវឌ្ឍធនធានមនុស្ស នៅក្នុងសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ នៅថ្ងៃទី២៨-២៩ ខែមីនា ឆ្នាំ២០២៤ ក្រសួងបានពិភាក្សាយ៉ាងល្អិតល្អន់លើមូលបទ «កំណែទម្រង់ផ្ទៃក្នុងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ៖ បង្កើនប្រសិទ្ធភាព ផលិតភាព និងគុណភាពការងារ»។ ក្រោមមូលបទនេះ ថ្នាក់ដឹកនាំក្រសួង បានផ្ដោតការពិភាក្សាលើប្រធានបទគន្លឹះចំនួនពីរ គឺ៖ (១) ការងារកំណែទម្រង់ផ្ទៃក្នុងក្រសួង និង (២) ការងារកំណែទម្រង់ស្ថានតំណាងកម្ពុជានៅបរទេស។

ចំពោះការងារពង្រឹងសមត្ថភាពមន្ត្រី ក្រសួងបានបញ្ជូនមន្ត្រីឱ្យចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន១១នាក់ និងនៅក្រៅប្រទេសចំនួន២១នាក់ ព្រមទាំងបានរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីនៅវិទ្យាស្ថានជាតិការទូតចំនួន២១៧នាក់ ដែលក្នុងនោះ វិទ្យាស្ថានបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការទូតសេដ្ឋកិច្ច វគ្គបណ្តុះបណ្តាលភាសាចិននិងថៃ និងបានបញ្ចប់វគ្គសិក្សាភាសាអេស្ប៉ាញតាមប្រព័ន្ធអនឡាញ ព្រមទាំងបានសហការជាមួយស្ថានទូតអូស្ត្រាលី និង Australia Award រៀបចំវគ្គបណ្តុះបណ្តាលចំនួន៣វគ្គ រួមមាន៖ (១) Effective Writing Skills for Diplomacy and International Relations (២) Introduction to Futures Analysis និង (៣) Effective Public Speaking & Strategic Presentation សម្រាប់មន្ត្រីក្រសួង និងស្ថាប័នពាក់ព័ន្ធផងដែរ។

ក្រៅពីនេះ វិទ្យាស្ថានបានរៀបចំសិក្ខាសាលាស្តីពី Crisis Management ដែលមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំក្រសួង ឯកអគ្គរាជទូត និងអគ្គកុងស៊ុលកម្ពុជានៅបរទេស ព្រមទាំងបានសហការជាមួយស្ថានទូតរុស្ស៊ី រៀបចំបាឋកថាស្តីពី Russia's Foreign Policy in the Asia Pacific Region and Russia-Cambodia relations ដែលផ្តល់បទឧទ្ទេសនាមដោយ **ឯកឧត្តម អាណាតូលី បូរ៉ូវីក** ឯកអគ្គរដ្ឋទូតរុស្ស៊ីប្រចាំកម្ពុជាផងដែរ។

ថ្ងៃ សុក្រ ១១ កើត ខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០២៤

**ជ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**ជុំ សុន្ទរី**